ស្កេនដើម្បីមើលមេរៀន

San Sochea Official

មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ១១

# ៨ - ទោសចេតសិក (Hatred)

ទុស្សតីតិ = ទោសោ ឈ្មោះថា ទោសៈ ព្រោះអត្ថថា ប្រទូសរ៉ាយ។

ក្នុងវិសុទ្ធិមគ្គ ពោលថា ទុស្សន្តិ តេន សយំ វា ទុស្សតិ ទុស្សនមត្តមេវ វា តន្តិ = ទោសោ ឈ្មោះថា ទោសៈ ព្រោះអត្ថថា ជាហេតុប្រទូសរ៉ាយសត្វ ឬឈ្មោះថា ទោសៈ ព្រោះអត្ថថា ប្រទូសរ៉ាយខ្លួនឯង ឬថា ត្រឹមតែប្រទូសរ៉ាយប៉ុណ្ណោះ ក៏ឈ្មោះថា ទោសៈ ។

** ទោសៈ នេះគប្បីឃើញដូចជាទឹកមូត្រស្អុយលាយដោយថ្នាំពិស។*

# លក្ខណាទិចតុក្កៈរបស់ទោសៈ

១ - ចណ្ឌិកលក្ខណោ — មានការកាច ជាលក្ខណៈ ដូចអាសិរិពិសដែលត្រូវគេវាយ

២ - វិសប្បនរសោ — មានការក្រហល់ក្រហាយ ជាកិច្ច ដូចត្រូវថ្នាំពិសជ្រាបចូល

អត្តនោ និស្សយទហនរសោ វា — ឬមានការដុតកំដៅទីនៅរបស់ខ្លួន ជាកិច្ច ដូចភ្លើងឆេះព្រៃ

៣ - ទុស្សនបច្ចុប្បដ្ឋានោ — មានការប្រទូសរ៉ាយ ជាអាការប្រាកដ ដូចសត្រូវបានឱកាស

៤ - អាឃាតវត្ថុបទដ្ឋានោ — មានអាឃាតវត្ថុ ជាហេតុជិត។

# អាឃាតវត្ថុ ១០

| | |
|---|---|
| ១. គំនុំកើតឡើងថា | ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ |
| ២. គំនុំកើតឡើងថា | ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ |
| ៣. គំនុំកើតឡើងថា | ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ |
| ៤. គំនុំកើតឡើងថា | ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ |
| ៥. គំនុំកើតឡើងថា | ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ |

៦. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ

៧. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គល មិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ

៨. គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គល មិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ

៩. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គល មិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ

១០. សេចក្តីក្រោធកើតឡើងក្នុងទីមិនគួរ ដូចពេលដែលដើរជំពប់ ឬ ជាន់បន្លាជាដើម ។

# ៩ - ឥស្សាចេតសិក (Jealousy)

ឥស្សតីតិ = ឥស្សា ឈ្មោះថា ឥស្សា ព្រោះ ឫស្យា ឬ ច្រណែន។

ឥស្សា នេះច្រណែនគ្នា មិនឲ្យអ្នកដទៃបានលាភសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន និងការបូជាជាដើម។

# លក្ខណាទិចតុក្កៈរបស់ឥស្សា

១ - បរសម្បត្តីនំ ឧស្សូយនលក្ខណា មានការច្រណែនសម្បត្តិ (អ្វីដែលល្អ) របស់អ្នកដទៃ ជាលក្ខណៈ

២ - តត្ថេវ អនភិរតិរសា មានការមិនត្រេកអរក្នុងសម្បត្តិរបស់អ្នកដទៃ ជាកិច្ច

៣ - វិមុខភាវបច្ចុប្បដ្ឋានា មានការបែរមុខចេញ ជាអាការប្រាកដ

៤ - បរសម្បត្តិបទដ្ឋានា មានសម្បត្តិអ្នកដទៃ ជាហេតុជិត ។

# ១០ - មច្ឆរិយចេតសិក (Avarice)

មច្ឆេរស្ស ភាវោ = មច្ឆរិយំ ភាវៈនៃបុគ្គលអ្នកកំណាញ់ ឈ្មោះថា មច្ឆរិយៈ។

យោជនា អធិប្បាយថា៖

ធម្មជាតិដែលប្រព្រឹត្តទៅដោយអាការថា "សេចក្តីអស្ចារ្យនេះ ចូរកុំមានដល់ពួកជនដទៃ សេចក្តីអស្ចារ្យនេះ ចូរមានដល់យើងប៉ុណ្ណោះ" ដូច្នេះ ឈ្មោះថា មច្ឆរិយៈ។

** បណ្ឌិតគប្បីឃើញមច្ឆរិយៈថា ជាសេចក្តីពិការរបស់ចិត្ត ។*

# មច្ឆរិយៈ ៥ យ៉ាង ៖

| | |
|---|---|
| ១ - អាវាសមច្ឆរិយំ | សេចក្តីកំណាញ់អាវាស |
| ២ - កុលមច្ឆរិយំ | សេចក្តីកំណាញ់ត្រកូល |
| ៣ - លាភមច្ឆរិយំ | សេចក្តីកំណាញ់លាភ |
| ៤ - វណ្ណមច្ឆរិយំ | សេចក្តីកំណាញ់វណ្ណៈ *(ពណ៌សម្បុរ និងសេចក្តីសរសើរ)* |
| ៥ - ធម្មមច្ឆរិយំ | សេចក្តីកំណាញ់ធម៌ *(បរិយត្តិធម៌ និងបដិវេធធម៌)* |

# លក្ខណាទិចតុក្កៈរបស់មច្ឆរិយៈ

១ - លទ្ធានំ វា លភិតព្វានំ អត្តនោ សម្បត្តីនំ និគូហណលក្ខណំ មានការបិទបាំងសម្បត្តិរបស់ខ្លួនដែលបានហើយ ឬដែលគួរបានជាលក្ខណៈ

២ - តាសំយេវ បរេហិ សាធារណភាវអក្ខមនរសំ មានការមិនពេញចិត្តក្នុងការឲ្យសម្បត្តិរបស់ខ្លួនទៅជាសាធារណៈដល់ជនដទៃ ជាកិច្ច

៣ - សំកោចនបច្ចុប្បដ្ឋានំ  មានការធ្វើមុខក្រញូវ ឬមិនអើពើជាអាការប្រាកដ

៤ - អត្តនោ សម្បត្តិបទដ្ឋានំ មានសម្បត្តិរបស់ខ្លួន ជាហេតុជិត។

# ១១ - កុក្កុច្ចចេតសិក (Worry)

កុកតស្ស ភាវោ បវត្តនិមិត្តំ = កុក្កុច្ចំ ភាវៈ គឺនិមិត្ត ជាទីប្រព្រឹត្តទៅ
នៃកម្មដែលបណ្ឌិតខ្ពើម ឈ្មោះថា កុក្កុច្ចៈ។

កុក្កុច្ចៈ នេះ ជាកង្វល់ចិត្ត ដោយប្រារព្ធកម្ម គឺទុច្ចរិតដែលធ្វើ
ហើយនិង សុចរិតដែលមិនបានធ្វើ ជាកម្មដែលបណ្ឌិតស្អប់។

** គប្បីឃើញកុក្កុច្ចៈនេះ ដូចមនុស្សជាទាសៈ ដែលមិនអាចប្រព្រឹត្ត
តាមទំនើងចិត្តខ្លួន។*

# លក្ខណាទិចតុក្កៈរបស់កុក្កុច្ចៈ

| | |
|---|---|
| ១ - បច្ចានុតាបនលក្ខណំ | មានការក្ដៅក្រហាយចិត្តជាខាងក្រោយ ជាលក្ខណៈ |
| ២ - កតាកតានុសោចនរសំ | មានការសោកសៅរឿយៗក្នុងអំពើបាបដែលធ្វើហើយ និងបុណ្យដែលនៅមិនទាន់បានធ្វើ ជាកិច្ច |
| ៣ - វិប្បដិសារបច្ចុប្បដ្ឋានំ | មានការស្ដាយក្រោយ ជាអាការប្រាកដ |
| ៤ - កតាកតបទដ្ឋានំ | មានបាបដែលធ្វើហើយ និងបុណ្យដែលមិនទាន់បានធ្វើ ជាហេតុជិត។ |